**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកែប**

លេខ:...០៣១.../១៦ ដក.បក


ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខ:.............
មកដល់ថ្ងៃ......ខែ......ឆ្នាំ......
ម៉ោង.............


# ដីកា

# ស្តីពី

# ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ របស់រដ្ឋបាលខេត្ត

## អភិបាល នៃគណៈអភិបាលខេត្ត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២សន/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ សន/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២៨ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ សន/រកម/០៥០៨/០១៧ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១២/៧០៩ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តកែប
- យោងលិខិតលេខ១៥២០ សជណ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈនៅថ្នាក់រដ្ឋបាលរាជធានី ខេត្ត ដើម្បីជំរុញការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃការអនុវត្តកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ ឆ្នាំ២០១៥-២០១៨
- យោងសេចក្តីសម្រេចលេខ ០៤៣ សសរ/១៤ខក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ របស់សាលាខេត្តកែប ស្តីពីការបែងចែកតួនាទីភារកិច្ច និងរបៀបរបបធ្វើការងារជូនគណៈអភិបាលខេត្តកែប និងអនុលោមភាពលេខ ០៤៣ សរ.សណ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០១៤ របស់ក្រសួងមហាផ្ទៃ ✓

# សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត ដែលមានសមាសភាពដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-ឯកឧត្តម | **កែន** | **សត្ថា** | អភិបាល នៃគណៈអភិបាលខេត្ត | ប្រធាន |
| ២-លោក | **សោម** | **ពិសិដ្ឋ** | អភិបាលរង នៃគណៈអភិបាលខេត្ត | អនុប្រធាន |
| ៣-លោក | **ព្រុំ** | **គន្ធិ** | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៤-លោក | **លី** | **សារឹម** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៥-លោក | **តឹក** | **សារ៉េត** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ៦-លោក | **ឈុន** | **ច័ន្ទវ៉ាន់ថុន** | នាយកទីចាត់ការអន្តរវិស័យ | សមាជិក |
| ៧-លោកស្រី | **យ៉េម** | **គឹមហេង** | នាយកទីចាត់ការរដ្ឋបាល | សមាជិកា |
| ៨-លោក | **ស្ងួន** | **ភាព** | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ៩-លោក | **ចាន់** | **សូទី** | នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១០-លោក | **ឃៀក** | **សារ៉ែន** | ប្រធានអង្គភាពលទ្ធកម្មរដ្ឋបាលខេត្ត | សមាជិក |
| ១១-លោក | **កែវ** | **ហុង** | ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១២-លោក | **ឈុន** | **ហេង** | ប្រធានរតនាគារខេត្ត | សមាជិក |
| ១៣-លោកស្រី | **ទិត** | **សុខា** | អភិបាលនៃគណៈអភិបាល ក្រុងកែប | សមាជិកា |
| ១៤-លោកស្រី | **គឹម** | **ចន្ធី** | អភិបាលនៃគណៈអភិបាលស្រុកដំណាក់ចង្អើរ | សមាជិកា |
| ១៥-លោក | **មិត្ត** | **ណារ៉ាក់** | ប្រធានការិ.រដ្ឋបាលនិងហិរញ្ញវត្ថុនៃមន្ទីរ (មស.ខក) | ជនបង្គោល |
| ១៦-លោក | **ស៊ីន** | **រ័តនា** | ប្រធានការិ.ក្របខ័ណ្ឌ និងបណ្តុះបណ្តាលនៃមន្ទីរ (មស.ខក) | ជនបង្គោល |

**ប្រការ ២.-**

ក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈថ្នាក់ខេត្ត មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សា និងគណៈអភិបាលខេត្ត ក្នុងការគ្រប់គ្រង និងដឹកនាំគ្រប់ការងារពាក់ព័ន្ធនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់ថ្នាក់ក្រោមជាតិ។
- សម្របសម្រួលការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ។
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្ត។

-រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពឲ្យបានទៀងទាត់រៀងរាល់ត្រីមាស មកលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល-សាធារណៈ។

-រៀបចំរបាយការណ៍ ស្តីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈជូនក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈក្រសួងមហាផ្ទៃ ដើម្បីធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជ្រាប និងផ្តល់គោលការណ៍ណែនាំអនុវត្ត។

-ផ្តល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោល ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធា-រណៈ នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

-តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយនឹងដីកានេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយករដ្ឋបាលសាលាខេត្ត គ្រប់នាយកទីចាត់ការ ប្រធានអង្គភាពចំណុះឲ្យរចនាសម្ព័ន្ធរដ្ឋបាលខេត្ត មន្ទីរអង្គភាពពាក់ព័ន្ធជុំវិញខេត្ត និងសាមីខ្លួនដូចមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តដីកានេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

ធ្វើនៅខេត្តកែប, ថ្ងៃទី...១៥...ខែ...៧...ឆ្នាំ២០១៦

**អភិបាល**

កែន.សត្ថា

***កន្លែងទទួល៖***

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រតនាគារជាតិ
- ក្រុមប្រឹក្សាខេត្ត

  *«ដើម្បីគោរពជូនជ្រាប»*
- ដូចប្រការ៤ *« ដើម្បីអនុវត្ត »*
- ឯកសារ-កាលប្បវត្តិ